ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ២៧៤ សជណ.អគ

CAMBODIA
Kingdom of Wonder
feel the warmth

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងប្រណាំង "China Ready លើកទី០១ (1st China Ready Contest)" ឆ្នាំ២០១៧

### I. សេចក្តីផ្តើម

ក្នុងគោលបំណងពង្រឹងឧស្សាហកម្មទេសចរណ៍កម្ពុជាដើម្បីត្រៀមទទួលស្វាគមន៍ទេសចរចិន និងចូលរួមអភិវឌ្ឍទេសចរណ៍កម្ពុជាសំដៅសម្រេចឲ្យបានកម្ពុជាទទួលទេសចរចិន ២លាននាក់ ក្នុងឆ្នាំ២០២០ ក្រសួងទេសចរណ៍ សូមជម្រាបជូនដំណឹងដល់ប្រតិបត្តិករ និងធុរជនក្នុងវិស័យទេសចរណ៍ដែលកំពុងចាប់យកទីផ្សារទេសចរណ៍ចិនទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងទេសចរណ៍នឹងដាក់ចេញនូវចលនាប្រឡងប្រណាំង "China Ready លើកទី០១" សម្រាប់ឆ្នាំ២០១៧-២០១៨ ដើម្បីធ្វើការស្វែងរក និងលើកទឹកចិត្តដល់ប្រតិបត្តិករទេសចរណ៍ដែលឆ្នើមក្នុងការផ្តល់សេវាកម្មជូនទេសចរចិន ក៏ដូចជាក្នុងគោលបំណងជំរុញឲ្យប្រតិបត្តិករទេសចរណ៍ដែលមិនទាន់បានដាក់ពាក្យស្នើសុំប្រព័ន្ធវាយតម្លៃបញ្ជាក់កម្រិតគុណភាពសេវាកម្មទេសចរណ៍ទទួលទេសចរចិន (China Ready Accreditation System) ធ្វើការស្នើសុំការទទួលស្គាល់ពីក្រសួងទេសចរណ៍។

### II. យន្តការនៃការប្រឡងប្រណាំង

ចលនាប្រឡងប្រណាំង China Ready ធ្វើឡើងដោយផ្អែកលើការវាយតម្លៃរបស់ទេសចរជនជាតិចិនទៅលើសេវាកម្មទេសចរណ៍ផ្តល់ដោយបេក្ខភាព។ ប្រតិបត្តិករទេសចរណ៍ដែលបម្រើសេវាកម្មដូចជាសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ សេវាកម្មស្នាក់នៅ សេវាកម្មដឹកជញ្ជូនទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ សេវាកម្មកម្សាន្ត ការីទេសចរណ៍ និងទីភ្នាក់ងារទេសចរណ៍ ផ្សារទំនើប និងហាងលក់វត្ថុអនុស្សាវរីយ៍ដែលទទួលបានការទទួលស្គាល់គុណភាពសេវាកម្មទេសចរណ៍តម្រូវឲ្យដាក់ពាក្យចូលរួមប្រឡងប្រណាំង "China Ready" សម្រាប់ឆ្នាំ២០១៧។

### III. ដំណើរការនៃការប្រឡងប្រណាំង

ប្រតិបត្តិករទេសចរណ៍អាចធ្វើការស្នើសុំចូលរួមជាបេក្ខភាពក្នុងចលនាប្រឡងប្រណាំង "China Ready លើកទី០១" ដោយនីតិវិធីស្នើសុំ និងវាយតម្លៃផ្តល់ជ័យលាភីនោះមានដំណាក់កាលដូចខាងក្រោម៖

- **ដំណាក់កាលទី១ ការដាក់ពាក្យ៖** បេក្ខភាពត្រូវដាក់ពាក្យសុំ និងផ្ញើមកកាន់ក្រសួងទេសចរណ៍រាល់ថ្ងៃក្នុងម៉ោងធ្វើការ ឬតាមរយៈគេហទំព័រ www.cambodia-chinaready.org ដោយមានភ្ជាប់មកជាមួយឯកសារពាក់ព័ន្ធ។ **ការដាក់ពាក្យស្នើសុំនឹងត្រូវបញ្ចប់នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៧។**
- **ដំណាក់កាលទី២ ការត្រៀមវាយតម្លៃ៖** ***ចាប់ពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៧*** មជ្ឈមណ្ឌលទ្រទ្រង់ China Ready នៃក្រសួងទេសចរណ៍នឹងធ្វើការបូកសរុបចំនួនបេក្ខភាព និងបង្កើត



អគារលេខ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

គណនីនៅលើគេហទំព័រ www.cambodia-chinaready.org ក៏ដូចជា QR Code ជូនគ្រប់បេក្ខភាព ដោយក្នុងគណនីនីមួយៗនឹងមានភ្ជាប់ជាមួយនូវកម្រងសំណួរសម្រាប់ទេសចរចូលធ្វើការវាយតម្លៃ និងផ្ដល់ពិន្ទុ (Vote) ទៅតាមកម្រងសំណួរទាំងនោះ។

- **ដំណាក់កាលទី៣ ការវាយតម្លៃ៖** ***ចាប់ពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧ ដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧*** បេក្ខភាពនឹងទទួលការវាយតម្លៃពីទេសចរ និងអតិថិជនរបស់ខ្លួនដោយគិតពីថ្ងៃដែលក្រសួងទេសចរណ៍ផ្ដល់គណនី និង QR Code ជូន។
- **ដំណាក់កាលទី៤ លទ្ធផលប្រឡងប្រណាំង៖** មជ្ឈមណ្ឌលទ្រទ្រង់ China Ready នៃក្រសួងទេសចរណ៍នឹងពិគ្រោះបូកសរុបពិន្ទុរបស់បេក្ខភាពទាំងអស់ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ។ លទ្ធផលជ័យលាភីចំនួន ១០ ដែលទទួលបានពិន្ទុខ្ពស់ជាងគេក្រោយការវាយតម្លៃក្នុងចំណោមបេក្ខភាពទាំងអស់ (Top 10) និងធ្វើការប្រកាសចែកជ័យលាភីជូនក្នុងឱកាសវេទិកា China Ready លើកទី០២ នៅថ្ងៃទី៣០-៣១ ខែតុលា ឆ្នាំ ២០១៧។

ចំពោះព័ត៌មានលម្អិត សូមទំនាក់ទំនងមកទីស្ដីការក្រសួងទេសចរណ៍/មជ្ឈមណ្ឌលទ្រទ្រង់ China Ready ឬ ទំនាក់ទំនងតាមទូរស័ព្ទលេខ **០៨៧ ២៣៣ ២២៣** ឬតាមរយៈ:

- សារអេឡិចត្រូនិច ៖ info@cambodia-chinaready.com
- គេហទំព័រ ៖ www.cambodia-chinaready.org

ទទួលបានសេចក្ដីជូនដំណឹងនេះ សូម **លោក-លោកស្រី** ដែលជាប្រតិបត្តិករ និងធុរជនដែលចាប់យកទីផ្សារទេសចរណ៍ចិនក្នុងវិស័យទេសចរណ៍ទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងសូមចូលរួមក្នុងការប្រឡងប្រណាំងខាងលើនេះឲ្យបានផុសផុល។

**ក្រសួងទេសចរណ៍**